**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២៣២ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការគ្រប់គ្រងការផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញនិងសេវា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញនិងសេវា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៦ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីយន្តការ បែបបទ និងនីតិវិធីក្នុងការគ្រប់គ្រងការផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញនិងសេវា ដើម្បីការពារអ្នកប្រើប្រាស់និងជំរុញឱ្យមានការប្រកួតប្រជែងប្រកបដោយសុចរិត។

**មាត្រា២ ._**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះការផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញនិងសេវា តាមគ្រប់ប្រភេទ គ្រប់ទម្រង់ និងគ្រប់មធ្យោបាយ រួមទាំងតាមមធ្យោបាយឌីជីថល នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ ._**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- **ការផ្សាយពាណិជ្ជកម្ម** សំដៅដល់ការផ្សព្វផ្សាយជាសាធារណៈឬការផ្សព្វផ្សាយទៅកាន់ក្រុមណាមួយក្នុងចំណោមសាធារណជន ទោះតាមទម្រង់និងមធ្យោបាយណាក៏ដោយ ក្នុងគោលបំណងជំរុញការផ្គត់ផ្គង់ទំនិញឬសេវា ឬការលក់ ឬការផ្តល់សិទ្ធិប្រត្យក្សលើអចលនទ្រព្យ។

២- **កន្លែងសាធារណៈ** សំដៅដល់ទីកន្លែងឬអគារសាធារណៈដែលសាធារណជនអាចចេញចូលបាន។

៣- **គំរូផលិតផល** សំដៅដល់ផលិតផលក្នុងបរិមាណតិចតួចដែលត្រូវបានផ្តល់ឱ្យអតិថិជន ដើម្បីសាកល្បងដោយឥតគិតថ្លៃ។

៤- **ឆ្នោតផ្សងសំណាង** សំដៅដល់បណ្ណផ្សងសំណាងដែលអ្នកផ្គត់ផ្គង់បានភ្ជាប់ជាមួយនឹងផលិតផលទំនិញឬសេវា។

៥- **បុគ្គលស្នើសុំផ្សាយពាណិជ្ជកម្ម** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលបានដាក់ពាក្យស្នើសុំអាជ្ញាបណ្ណផ្សាយពាណិជ្ជកម្មពីក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។

៦- **បណ្ណផ្សព្វផ្សាយ** សំដៅដល់បណ្ណដែលអ្នកផ្គត់ផ្គង់និងអ្នកចែកចាយបានជូនជាសេចក្តីជូនដំណឹងឬផ្សព្វផ្សាយលើផលិតផលទំនិញនិងសេវា សម្រាប់បង្ហាញដល់សាធារណជន។

៧- **លក្ខខណ្ឌតម្រូវផ្សាយពាណិជ្ជកម្មមានរង្វាន់** សំដៅដល់ការបញ្ជាក់អំពីផលិតផលទំនិញសរុបដែលមានរង្វាន់ ប្រភេទរង្វាន់ ចំនួនរង្វាន់សរុប សុពលភាពនៃការផ្តល់រង្វាន់ ឯកសារ ឬព័ត៌មានដែលជាកាតព្វកិច្ចរបស់បុគ្គលស្នើសុំអាជ្ញាបណ្ណផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញនិងសេវាដែលត្រូវរង្វាន់និង/ឬឈ្នះរង្វាន់ ជូនដល់ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។

៨- **លិខិតបញ្ជាក់អនុលោមភាពនៃការផ្សាយពាណិជ្ជកម្ម** សំដៅដល់លិខិតបញ្ជាក់ដែលចេញដោយអគ្គនាយកដ្ឋាន **ក.ប.ប.** នៃក្រសួងពាណិជ្ជកម្ម សម្រាប់ផ្តល់ជូនបុគ្គលផ្សាយពាណិជ្ជកម្ម ដើម្បីបញ្ជាក់អំពីភាពត្រឹមត្រូវនៃអត្ថបទឬគម្រោងនៃការផ្សាយពាណិជ្ជកម្មឬស្ពតនៃការផ្សាយពាណិជ្ជកម្មដែលស្របតាមច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ឬបទប្បញ្ញត្តិជាធរមាន។

៩- **វត្ថុអនុស្សាវរីយ៍** សំដៅដល់ឧបករណ៍ សម្ភារ ឬវត្ថុអ្វីមួយដែលអ្នកផ្គត់ផ្គង់បានភ្ជាប់ជាមួយទំនិញឬសេវាសម្រាប់ផ្គត់ផ្គង់ដោយឥតគិតថ្លៃ។

១០- **សំបកវេចខ្ចប់** សំដៅដល់រាល់ទម្រង់វេចខ្ចប់ស្រោបពីខាងក្រៅលើផលិតផលទំនិញដូចជា គំរបដប កំប៉ុង ប្រអប់ ថង់ កេស ដោយរាប់បញ្ចូលទាំងផលិតផលទំនិញនាំចូលនិងផលិតផលទំនិញក្នុងស្រុក។

១១- **អាជ្ញាបណ្ណផ្សាយពាណិជ្ជកម្ម** សំដៅដល់ប្រកាស ឬលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ដែលអនុញ្ញាតឱ្យផ្សាយពាណិជ្ជកម្មដោយក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។

១២- **អត្ថបទផ្សាយពាណិជ្ជកម្ម** សំដៅដល់ពាក្យពេចន៍ ខ្លឹមសារ អត្ថន័យ សារអេឡិចត្រូនិកជាអក្សរ សំឡេង ចម្រៀង កំណាព្យ ស្នូត្រ ចាប៉ី អាយ៉ៃ កំប្លែង សំឡេងពេទ៌ទូរស័ព្ទ វីដេអូខ្លីៗ គំនូរជីវចល 3D 4D 5D ឬសំនួនវោហារស័ព្ទផ្សេងទៀត ដែលមានបំណងផ្សាយពាណិជ្ជកម្មផ្គត់ផ្គង់ផលិតផលទំនិញនិងសេវា។

១៣- **អគ្គនាយកដ្ឋាន ក.ប.ប.** សំដៅដល់អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ នៃក្រសួងពាណិជ្ជកម្ម។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤.-**

ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ មានសមត្ថកិច្ចក្នុងការផ្តល់អាជ្ញាបណ្ណផ្សាយពាណិជ្ជកម្ម ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ក្រសួងពាណិជ្ជកម្មមានសមត្ថកិច្ចក្នុងការផ្តល់លិខិតបញ្ជាក់អនុលោមភាពនៃការផ្សាយពាណិជ្ជកម្ម ទៅតាមសំណើរបស់បុគ្គលស្នើសុំផ្សាយពាណិជ្ជកម្ម ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា៥.-**

ក្រសួងពាណិជ្ជកម្ម មានសមត្ថកិច្ចត្រួតពិនិត្យ វាយតម្លៃលើអនុលោមភាពនៃការផ្សាយពាណិជ្ជកម្ម និងចាត់វិធានការចំពោះភាពមិនសុចរិតនៃការផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញនិងសេវា។

ក្នុងករណីចាំបាច់ ក្រសួងពាណិជ្ជកម្មត្រូវសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។

## ជំពូកទី៣
## ប្រភេទ ទម្រង់ និងមធ្យោបាយនៃការផ្សាយពាណិជ្ជកម្ម

**មាត្រា៦.-**

ការផ្សាយពាណិជ្ជកម្មត្រូវបានចែកចេញជាពីរប្រភេទ គឺការផ្សាយពាណិជ្ជកម្មដោយមិនផ្តល់រង្វាន់និងការផ្សាយពាណិជ្ជកម្មដោយផ្តល់រង្វាន់។

**មាត្រា៧.-**

ការផ្សាយពាណិជ្ជកម្មដោយផ្តល់រង្វាន់ រួមមាន ការផ្តល់រង្វាន់ជាវត្ថុអនុស្សាវរីយ៍និង/ឬឆ្នោតផ្សងសំណាង និងរង្វាន់ផ្សេងៗទៀតដែលភ្ជាប់នឹងផលិតផលទំនិញនិងសេវា។

បុគ្គលស្នើសុំផ្សាយពាណិជ្ជកម្ម ត្រូវបង្កលក្ខណៈងាយស្រួលដល់អ្នកឈ្នះរង្វាន់និងអ្នកត្រូវរង្វាន់ ដើម្បីទទួលបាននូវរង្វាន់ពិតប្រាកដ។

បុគ្គលស្នើសុំផ្សាយពាណិជ្ជកម្មដោយផ្តល់រង្វាន់មានកាតព្វកិច្ចគោរពតាមលក្ខខណ្ឌតម្រូវ ដូចខាងក្រោម៖

- បញ្ជាក់អំពីផលិតផលទំនិញសរុបដែលមានរង្វាន់
- ប្រភេទរង្វាន់និងចំនួនរង្វាន់សរុប
- សុពលភាពនៃការផ្តល់រង្វាន់
- ផ្តល់ទីតាំងជាក់លាក់ដែលត្រូវផ្តល់រង្វាន់
- ផ្តល់ឯកសារឬព័ត៌មានស្តីពីអត្តសញ្ញាណអ្នកឈ្នះរង្វាន់និងអ្នកត្រូវរង្វាន់ជាប្រចាំខែនិងប្រចាំឆ្នាំ។

**មាត្រា៨.-**

ទម្រង់និងមធ្យោបាយនៃការផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញនិងសេវា មានជាអាទិ៍៖

១- តាមប្រព័ន្ធផ្សព្វផ្សាយសោតទស្សន៍ មាន : ទូរទស្សន៍និងបណ្តាញផ្សព្វផ្សាយអេឡិចត្រូនិកគ្រប់ប្រភេទក្នុងបរិបទឧស្សាហកម្ម៤.០ រួមទាំងទូរទស្សន៍ផ្កាយរណប ទូរទស្សន៍ខ្សែកាប ផ្កាយរណបថាសទូរទស្សន៍។

២- តាមប្រព័ន្ធអេឡិចត្រូនិក មាន : វិបសាយ អ៊ីម៉ែល សារអេឡិចត្រូនិក ជាអក្សរ ជាសំឡេង ជារូបភាព សំឡេងរោទិ៍ ទូរស័ព្ទ បណ្ដាញទំនាក់ទំនងសង្គម កម្មវិធីលើកុំព្យូទ័រ ទូរស័ព្ទឬឧបករណ៍ឆ្លាតផ្សេងៗទៀត កម្មវិធីស្វែងរកព័ត៌មានតាមអ៊ីនធឺណិត។

៣- ការបោះពុម្ព មាន : កាសែត ទស្សនាវដ្ដី ព្រឹត្តិបត្រ បណ្ណព័ត៌មាន។

៤- ការផ្សាយជាសំឡេង : ការឃោសនាជាសំឡេង វិទ្យុគ្រប់ប្រភេទ។

៥- ជាឧបករណ៍ផ្ទុកសំឡេងនិងរូបភាពគ្រប់ប្រភេទរួមមាន : ស៊ីឌី វីស៊ីឌី ឌីវីឌី វីអេ ខ្សែភាពយន្ត វីដេអូ គំនូរជីវចល 3D 4D 5D និងនាទីវប្បធម៌នានា។

៦- ការសំដែងលើឆាក : ការប្រគុំតន្ត្រី សិល្បៈ នាទីកំសាន្ត។

៧- ការដាក់តាំងបង្ហាញ : អេក្រង់អិលអ៊ីឌី អាហ្វីស ផ្ទាំងប៉ាណូ ផ្ទាំងព័ត៌មាន ផ្ទាំងរូបភាព បដា ខិត្តប័ណ្ណ ស្លាកយីហោ ការបិទផ្សាយនានា។

៨- បណ្ណផ្សព្វផ្សាយផលិតផលទំនិញនិងសេវា។

៩- ការលក់បញ្ចុះថ្លៃ ការលក់បញ្ចុះថ្លៃពិសេស ការលក់លាងឃ្លាំង និងការលក់ដោយថ្លៃកំណត់ដាក់លាក់។

១០- លើសំបកវេចខ្ចប់ទំនិញ។

១១- នៅតាមមជ្ឈមណ្ឌលដឹកជញ្ជូន មធ្យោបាយដឹកជញ្ជូននានា។

១២- នៅក្នុងអង្គប្រជុំ សិក្ខាសាលា វគ្គបណ្ដុះបណ្ដាល សន្និសីទសារព័ត៌មាន។

១៣- ការដាក់តាំងបង្ហាញជាសាធារណៈនូវរូបភាព គំរូផលិតផលនានា។

១៤- នៅតាមគ្រឹះស្ថានសិក្សា មជ្ឈមណ្ឌលកីឡា គ្រឹះស្ថានសុខាភិបាល គ្រឹះស្ថានសាសនា មជ្ឈមណ្ឌលពាណិជ្ជកម្ម មជ្ឈមណ្ឌលកំសាន្ត គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានឧស្សាហកម្ម។

១៥- ទីកន្លែងសាធារណៈ។

**មាត្រា៩ .-**

អត្ថបទផ្សាយពាណិជ្ជកម្មនិងទម្រង់នៃការផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញនិងសេវា ត្រូវប្រើប្រាស់ភាសានិងអក្សរខ្មែរជាគោល លើកលែងតែ៖

១- ម៉ាក ឬឈ្មោះត្រឹមត្រូវមានជាភាសាបរទេស ឬអក្សរបរទេសដែលមិនអាចជំនួសដោយភាសានិងអក្សរខ្មែរបាន។

២- សៀវភៅ វិបសាយ និងផលិតផលបោះពុម្ពផ្សាយ ប្រព័ន្ធផ្សព្វផ្សាយដោយបោះពុម្ព ត្រូវបានអនុញ្ញាតឱ្យបោះពុម្ពជាភាសាខ្មែរនិងភាសាបរទេស វិទ្យុ ទូរទស្សន៍ ផ្សាយជាភាសាខ្មែរនិងភាសាបរទេស។

ការផ្សាយពាណិជ្ជកម្មដែលមានទាំងអក្សរខ្មែរនិងអក្សរបរទេស ពុម្ពអក្សរខ្មែរត្រូវមានទំហំពីរដងធំជាងទំហំពុម្ពអក្សរបរទេស ហើយត្រូវដាក់នៅខាងក្រោមអក្សរខ្មែរជានិច្ច។

## ជំពូកទី៤

## អាជ្ញាបណ្ណផ្សាយពាណិជ្ជកម្ម និងលិខិតបញ្ជាក់អនុលោមភាពនៃការផ្សាយពាណិជ្ជកម្ម

### ផ្នែកទី១

### អាជ្ញាបណ្ណផ្សាយពាណិជ្ជកម្ម

**មាត្រា១០ .-**

បុគ្គលស្នើសុំផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញនិង/ឬសេវា ត្រូវសុំអាជ្ញាបណ្ណផ្សាយពាណិជ្ជកម្មស្របតាមការកំណត់របស់ច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា១១ .-**

ត្រូវបានហាមឃាត់រាល់ការផ្សាយពាណិជ្ជកម្ម ដែលមិនមានអាជ្ញាបណ្ណផ្សាយពាណិជ្ជកម្មពីក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ក្នុងករណីដែលអាជ្ញាបណ្ណផ្សាយពាណិជ្ជកម្មជាលក្ខខណ្ឌដែលមានកំណត់ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ផ្នែកទី២
## លិខិតបញ្ជាក់អនុលោមភាពនៃការផ្សាយពាណិជ្ជកម្ម

**មាត្រា១២ .-**

បុគ្គលស្នើសុំផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញនិង/ឬសេវា អាចសុំលិខិតបញ្ជាក់អនុលោមភាពនៃការផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញនិង/ឬសេវា មុននឹងដំណើរការផ្សាយពាណិជ្ជកម្ម។

ក្រសួងពាណិជ្ជកម្មត្រូវសម្រេចលើការស្នើសុំលិខិតបញ្ជាក់អនុលោមភាពនៃការផ្សាយពាណិជ្ជកម្មក្នុងរយៈពេល៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសំណើសុំ។

កម្រៃសេវាស្នើលិខិតបញ្ជាក់អនុលោមភាពនៃការផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញនិង/ឬសេវា ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

បែបបទនិងនីតិវិធីនៃការស្នើសុំលិខិតបញ្ជាក់អនុលោមភាពលើអត្ថបទផ្សាយពាណិជ្ជកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា១៣ .-**

បុគ្គលស្នើសុំឬបុគ្គលទទួលសិទ្ធិឱ្យចាត់ចែងផ្សាយពាណិជ្ជកម្ម ដែលមានបំណងផ្សាយពាណិជ្ជកម្មអំពីផលិតផលទំនិញនិង/ឬសេវារបស់ខ្លួនលើកម្មសិទ្ធិសាធារណៈឬឯកជន ត្រូវស្នើសុំការអនុញ្ញាតជាមុនពីកម្មសិទ្ធិករ អ្នកកាន់កាប់ ឬអ្នកគ្រប់គ្រង។

ការផ្សាយពាណិជ្ជកម្មនៅលើទីតាំងដែលមិនបានទទួលការអនុញ្ញាតពីកម្មសិទ្ធិករ អ្នកកាន់កាប់ ឬអ្នកគ្រប់គ្រង បុគ្គលស្នើសុំផ្សាយពាណិជ្ជកម្មឬបុគ្គលទទួលសិទ្ធិឱ្យចាត់ចែងផ្សាយពាណិជ្ជកម្ម ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

**មាត្រា១៤ .-**

លិខិតបញ្ជាក់អនុលោមភាពនៃការផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញនិង/ឬសេវា ដែលចេញដោយក្រសួងពាណិជ្ជកម្មត្រូវមានសុពលភាពមិនលើសពីរយៈពេល១(មួយ)ឆ្នាំ ទៅតាមអត្ថបទឬស្ពតផ្សាយពាណិជ្ជកម្មនីមួយៗ។

បុគ្គលស្នើសុំផ្សាយពាណិជ្ជកម្មអាចស្នើសុំបន្តសុពលភាពលិខិតបញ្ជាក់អនុលោមភាពនៃការផ្សាយពាណិជ្ជកម្ម ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ មុនពេលផុតសុពលភាព។

ក្នុងករណីដែលមានការផ្លាស់ប្តូរអត្ថបទឬស្ពតផ្សាយពាណិជ្ជកម្ម បុគ្គលស្នើសុំផ្សាយពាណិជ្ជកម្មអាចស្នើសុំលិខិតបញ្ជាក់អនុលោមភាពនៃការផ្សាយពាណិជ្ជកម្មជាថ្មី។

## ជំពូកទី៥
## ការហាមឃាត់ចំពោះការផ្សាយពាណិជ្ជកម្ម

**មាត្រា១៥ .-**

ត្រូវបានហាមឃាត់រាល់ការផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញនិងសេវា ដែលលិខិតបទដ្ឋានគតិយុត្តបានហាមឃាត់ធ្វើពាណិជ្ជកម្មនិង/ឬផ្សាយពាណិជ្ជកម្ម។

ប្រភេទផលិតផលទំនិញនិងសេវាផ្សេងទៀតដែលត្រូវហាមឃាត់ក្នុងការផ្សាយពាណិជ្ជកម្ម ត្រូវកំណត់ដោយក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។

**មាត្រា១៦ ..**

ការផ្សាយពាណិជ្ជកម្មដោយមិនផ្តល់រង្វាន់ក្តីឬផ្តល់រង្វាន់ក្តី ទោះតាមប្រភេទ ទម្រង់ និងមធ្យោបាយណាក៏ដោយ មិនត្រូវមានលក្ខណៈមិនពិត ភូតកុហក ពង្វាងការពិត ក្លែងបន្លំ ឬធ្វើឱ្យមានការភាន់ច្រឡំអំពីគុណភាពនិងសុវត្ថិភាពនៃផលិតផលទំនិញនិងសេវា។

**មាត្រា១៧ ..**

ត្រូវបានហាមឃាត់រាល់ការផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញនិងសេវា ដែលមានខ្លឹមសារដូចខាងក្រោម៖

១- បង្ហាញពីការសម្ងាត់របស់រដ្ឋ បង្កអន្តរាយដល់ឯករាជ្យជាតិ វិស័យការពារជាតិ វិស័យសន្តិសុខជាតិ សេដ្ឋកិច្ចជាតិ ទំនាក់ទំនងអន្តរជាតិ អធិបតេយ្យភាពជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម។

២- ធ្វើឱ្យប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូរជាតិ ទង់ជាតិ និមិត្តសញ្ញាជាតិ ភ្លេងជាតិ គ្រឹះស្ថានសាសនា ស្ថាប័នព្រះមហាក្សត្រ ស្ថាប័នជាតិ អង្គការជាតិនិងអន្តរជាតិ វីរបុរសជាតិ ថ្នាក់ដឹកនាំប្រទេស និងកេរ្តិ៍ឈ្មោះបុគ្គល។

៣- ប៉ះពាល់ដល់តម្លៃប្រវត្តិសាស្ត្រ ក្រមសីលធម៌ វប្បធម៌ ទំនៀមទម្លាប់ ប្រពៃណីជាតិ និងជំនឿសាសនា។

៤- បង្ហាញពីការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬពិការភាព។

៥- ជំរុញឱ្យកុមារគិត អនុវត្តតាម និយាយឬបញ្ចេញកាយវិការផ្ទុយពីទំនៀមទម្លាប់ ប្រពៃណី និងក្រមសីលធម៌ ជះឥទ្ធិពលអវិជ្ជមានដល់សុខភាព សុវត្ថិភាព ឬការអភិវឌ្ឍធម្មជាតិរបស់កុមារ។

៦- បង្ខំបុគ្គលដទៃឱ្យធ្វើការផ្សាយពាណិជ្ជកម្មជំនួសខ្លួនដោយមិនមានការស្ម័គ្រចិត្ត។

៧- ជួលបុគ្គលណាម្នាក់ឱ្យធ្វើការផ្សាយពាណិជ្ជកម្មភូតកុហកថាខ្លួនបានទទួលរង្វាន់ឬផលប្រយោជន៍ផ្សេងទៀតពីទំនិញនិងសេវា។

៨- យកខ្លឹមសារ ទម្រង់ ឬអត្ថបទរបស់បុគ្គលណាម្នាក់ដោយមិនទទួលបានការយល់ព្រម។

៩- ប្រៀបធៀបផលិតផលទំនិញនិងសេវារបស់ខ្លួនក្នុងចេតនាបង្អាប់ឬប៉ះពាល់ជាមួយនឹងផលិតផលទំនិញនិងសេវារបស់បុគ្គលផ្សេងទៀត។

១០- ប្រើពាក្យល្អបំផុត តែម្នាក់ លេខមួយ លើសគេ គ្មានគូប្រៀប ឬពាក្យដែលមានអត្ថន័យស្រដៀងគ្នាដោយគ្មានឯកសារត្រឹមត្រូវដែលបានបញ្ជាក់ដោយក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។

១១- ប៉ះពាល់ដល់សុខភាពនិងសុវត្ថិភាពអ្នកប្រើប្រាស់។

១២- បំពាននឹងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានផ្សេងទៀត។

**មាត្រា១៨ ..**

មិនត្រូវប្រើប្រាស់ការផ្សាយពាណិជ្ជកម្មដែលធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាពសាធារណៈ សុវត្ថិភាពចរាចរណ៍ និងសណ្តាប់ធ្នាប់សង្គម។

## ជំពូកទី៦
## ទណ្ឌកម្ម

**មាត្រា១៩ .-**

បុគ្គលដែលធ្វើការផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញនិងសេវា បំពាននឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្ម ដូចខាងក្រោម៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការព្យួរ ការដកហូត ឬការលុបចោលអាជ្ញាបណ្ណផ្សាយពាណិជ្ជកម្មនិង/ឬលិខិតបញ្ជាក់អនុលោមភាពនៃការផ្សាយពាណិជ្ជកម្ម
- ការព្យួរ ការដកហូត ឬការលុបចោលវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម។

ការព្រមានជាលាយលក្ខណ៍អក្សរនិងការព្យួរ ការដកហូត ឬការលុបចោលលិខិតបញ្ជាក់អនុលោមភាពនៃការផ្សាយពាណិជ្ជកម្ម ជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម។

ការព្យួរ ការដកហូត ឬការលុបចោលអាជ្ញាបណ្ណផ្សាយពាណិជ្ជកម្មនិង/ឬវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម អាជ្ញាបណ្ណឬលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។

គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់អាចស្នើសុំទៅក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីចាត់វិធានការព្យួរ ដកហូត ឬលុបចោលអាជ្ញាបណ្ណផ្សាយពាណិជ្ជកម្មនិង/ឬវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម និងចាត់វិធានការផ្អាកការប្រកបអាជីវកម្មជាបណ្ដោះអាសន្នស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ក្នុងករណីដែលបុគ្គលធ្វើការផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញនិងសេវា បានទទួលរងនូវការព្រមានជាលាយលក្ខណ៍អក្សរ ហើយមិនបានធ្វើការកែតម្រូវតាមការកំណត់ឬនៅតែបន្តប្រព្រឹត្តបំពាននឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ មន្ត្រីស៊ើបអង្កេតរបស់អគ្គនាយកដ្ឋាន **ក.ប.ប.** នៃក្រសួងពាណិជ្ជកម្មឬមន្ត្រីនៃក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីចេញសេចក្ដីសម្រេចក្នុងការព្យួរ ដកហូត ឬលុបចោលអាជ្ញាបណ្ណផ្សាយពាណិជ្ជកម្ម ឬលិខិតបញ្ជាក់អនុលោមភាពនៃការផ្សាយពាណិជ្ជកម្មនិង/ឬវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម។

**មាត្រា២០ .-**

ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ អាចចាត់វិធានការបន្ថែមចំពោះអំពើបំពាននឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះរួមមាន បញ្ឈប់ការផ្សព្វផ្សាយ ដកហូតអេក្រង់ផ្សព្វផ្សាយ ផ្ទាំងរូបភាព ផ្ទាំងប៉ាណូ ផ្ទាំងបដា ផ្ទាំងគំនូរ បណ្ណផ្សព្វផ្សាយ ឬរាល់មធ្យោបាយសម្រាប់ដំណើរការផ្សព្វផ្សាយលើផលិតផលទំនិញនិងសេវាផ្សេងៗទៀត ព្រមទាំងផ្អាកការប្រកបអាជីវកម្មជាបណ្ដោះអាសន្ន។

**មាត្រា២១ .-**

ការសម្រេចដាក់ទណ្ឌកម្មស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ មិនមែនជាឧបសគ្គដល់ការចោទប្រកាន់និងការផ្ដន្ទាទោសព្រហ្មទណ្ឌ ព្រមទាំងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានឡើយ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា២២ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៣ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១១កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ